# សេចក្តីអំពាវនាវ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ ចំពោះព្រះសង្ឃព្រះពុទ្ធសាសនាខ្មែរដែលឆាន់បារី សូមឈប់ឆាន់ដើម្បីសុខភាពនិងជាគំរូដ៏ល្អសំរាប់ពុទ្ធបរិស័ទខ្មែរ

website : www.hoksavann.org

ថ្ងៃទី២៣ ធ្នូ ២០០៦



ពុទ្ធសាសនិកជនខ្មែរបានទុកព្រះសង្ឃជាទីគោរពសក្ការៈរបស់ខ្លួន ។ បើព្រះសង្ឃអង្គណាដែលឆាន់បារី ពុំមែនគ្រោះថ្នាក់តែចំពោះខ្លួនលោកទេ គឺវានាំឲ្យគ្រោះថ្នាក់ដល់ពុទ្ធបរិស័ទ ដែលទៅធ្វើបុណ្យទាន ដោយសារតែការស្រូបយកផ្សែងបារីដែលព្រះសង្ឃឆាន់ ហើយជាគំរូមិនល្អដល់ពុទ្ធបរិស័ទផង ។ បារីអាចចាត់ចូលក្នុងប្រភេទសុរានៃសីល៥ដែលជាខហាម ព្រោះជាប្រភេទគ្រឿងពុលដូចគ្នា ។ ពុទ្ធសាសនាតែងតែសំដែងអំពីគុណានិងទោស គឺគុណាត្រូវអនុវត្ត ឯទោសត្រូវលះបង់ ។ យ៉ាងណាមិញ បារីចាត់ជាទោសដល់អ្នកជក់ ព្រោះនាំឲ្យកើតរោគ មិនតែប៉ុណ្ណោះនាំឲ្យគ្រោះថ្នាក់ដល់អ្នកនៅជុំវិញ ដែលស្រូបផ្សែងបារីពីអ្នកជក់ផង ។

តាមផ្លូវវេជ្ជសាស្ត្រ ដែលរកឃើញជាតិពុលនៅក្នុងបារីថ្នាំជក់ ជាពិសេសអង្គការសុខភាពពិភពលោកបានរកឃើញថា នៅក្នុងបារីមានជាតិម៉្យាងហៅថា Nicotine ដែលជាជាតិពុល មានសភាពដូចជាតិកំបោរហៅថា Alcaloide កាលណាវាផ្សំគ្នាច្រើន បង្កើតបានជា Insecticide ដែលគេយកជាតិនេះសំរាប់សម្លាប់សត្វល្អិត ។

ជាតិ Nicotine នេះ បណ្តាលឲ្យគ្រោះថ្នាក់ដល់អ្នកជក់សំខាន់ៗគឺ ៖

១- កើតរោគមហារីកក្នុងសួត ។

២- កើតជម្ងឺសរសៃនិងជម្ងឺបេះដូង (maladie Cardio Vasculaire) ។

៣- ធ្វើឲ្យសរសៃប្រសាទនិងខួរក្បាលរលាកទៅជាល្ងិល្ងើ (Toxicité neurologique) ។

៤- បើស្ត្រីមានផ្ទៃពោះ ទារកដែលកើតមកទៅជាស្គាំងស្គមខុសប្រក្រតី

ដោយ សារការស្រូបជាតិពុល ពីម្តាយដែលជក់បារី ។ល។

ដោយឃើញទោសទាំងនេះហើយ បានជាប្រទេសដែលជឿនលឿនក្នុងលោក គេពុំអនុញ្ញាតឲ្យផ្សាយពាណិជ្ជកម្មបារីនៅក្នុងវិទ្យុនិងទូរទស្សន៍ និងសារព័ត៌មានឡើយ ហើយកន្លែងសាធារណៈ គេហាមជក់បារីដាច់ខាត ។ មានប្រទេសខ្លះហាមពាណិជ្ជកម្មបារីទាំងស្រុងតែម្តង ។

## សូមធ្វើការអំពាវនាវ

១- ព្រះសង្ឃទាំងឡាយណាដែលឆាន់បារី គួរគប្បីឈប់ឆាន់ ដើម្បីជាសុខភាពផ្ទាល់ខ្លួនព្រះអង្គផង ហើយជាពិសេសទៅទៀត បានជាគំរូដ៏ល្អសំរាប់ពុទ្ធបរិស័ទខ្មែរយកតម្រាប់តាម ។

២- ចំណែកពុទ្ធបរិស័ទខ្មែរគួរឈប់ប្រគេនបារីលោក ព្រោះទានបារីនេះពុំបានបុណ្យទេ តែត្រូវបានបាបទៅវិញ ព្រោះប្រគេនគ្រឿងពុលដល់លោក ធ្វើឲ្យលោកកើតរោគ ។

ពិភពលោកបានដាក់ថ្ងៃ៣១ឧសភា ជាថ្ងៃពិភពលោកគ្មានថ្នាំជក់ ។ ក្រឡេកមកមើលរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលខ្មែរ មិនត្រឹមតែមិនទប់ស្កាត់ពាណិជ្ជកម្មបារីទេ ថែមទាំងបើកដោយចំហ ព្រមទាំងបើកឲ្យផ្សាយតាមវិទ្យុនិងទូរទស្សន៍ ព្រមទាំងតាមសារព័ត៌មានយ៉ាងទូលំទូលាយផង ។ ច្បាប់ស្តីអំពីការគ្រប់គ្រងគុណភាពសុវត្ថិភាពលើផលិតផលទំនិញដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃ២៩ឧសភាឆ្នាំ ២០០០ ហើយច្បាប់នេះបានត្រូវព្រះមហាក្សត្រឡាយព្រះហត្ថលេខាកាលពីថ្ងៃ២១មិថុនាឆ្នាំដដែលនោះ ពុំឃើញរាជរដ្ឋាភិបាលអនុវត្តតាមឡើយ ដោយបណ្តោយឲ្យនាំចូលស្រា បារី ដែលជាជាតិពុលគ្រប់ធុនគ្រប់ម៉ាកមកកម្ពុជា ។ ដូច្នេះបានន័យថា ក្រសួងសុខាភិបាលនិងរាជរដ្ឋាភិបាលខ្មែរសុខចិត្ត យកជីវិតប្រជាពលរដ្ឋទៅប្តូរយកប្រាក់ពន្ធបន្តិចបន្តួចពីពាណិជ្ជកម្មបារីនេះ ។ ប៉ុន្តែក្រសួងសុខាភិបាលខ្មែរបានធ្វើការស្រាវជ្រាវប៉ាន់ប្រមាណជូនទៅរាជរដ្ឋាភិបាលដើម្បីពិចារណា ដោយគិត១០ឆ្នាំ ពីឆ្នាំ១៩៩៧ដល់ឆ្នាំ២០០៧ ប្រាក់ចំណូលពីថ្នាំជក់បាន៦៥៩លានដុល្លារ ប៉ុន្តែប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ ដោយការចំណាយក្នុងការព្យាបាលអស់១០៧៩លានដុល្លារ ដូច្នេះរដ្ឋពុំចំណេញលើយ ថែមទាំងខាតបង់អស់៤១០លានដុល្លារ និងធ្វើឲ្យខូចសុខភាពប្រជាពលរដ្ឋ ដែលជាធនធានមនុស្សថែមទៀត ។ ដោយឃើញផលវិបាកអាក្រក់បែបនេះដល់ប្រទេស គួររាជរដ្ឋាភិបាលធ្វើច្បាប់លុបបំបាត់ពាណិជ្ជកម្មបារីនេះទាំងស្រុងតែម្តង ដូចជាប្រទេសខ្លះគេបានធ្វើរួចមកហើយ ។៚

❀ ❀

❀